**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ.......................បទ.........................

# សេចក្តីបំភ្លឺ
# ទាក់ទងនឹងច្បាប់ស្តីពីទូរគមនាគមន៍

ថ្មីៗនេះ មានការចុះផ្សាយព័ត៌មានអំពី**ការបកស្រាយមួយដែលផ្ទុយពីការពិត**នូវអត្ថន័យនៃច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានចូលជាធរមាននាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។

ពាក់ព័ន្ធនឹងករណីនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមធ្វើការបំភ្លឺជូនសាធារណជនបានជ្រាបដូចតទៅ ៖

## ទី១-ដំណើរការនៃការរៀបចំច្បាប់ស្តីពីទូរគមនាគមន៍៖

នៅក្នុងដំណើរការរៀបចំច្បាប់នេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានធ្វើការប្រជុំពិភាក្សា ពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ និងទទួលបាននូវធាតុចូលនានា ទាំងពីសំណាក់ក្របខណ្ឌផ្ទៃក្នុងក្រសួងខ្លួនឯង និងពីសំណាក់វិស័យឯកជន តំណាងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា អង្គការ Jica សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និងអន្តរក្រសួង ព្រមទាំងបានធ្វើការប្រៀបធៀប និងដកស្រង់យកនូវឧត្តមានុវត្តអំពីការបញ្ញត្តិច្បាប់ស្តីពីវិស័យទូរគមនាគមន៍នេះ នៅតាមបណ្តាប្រទេសនានា ជាអាទិ៍ ប្រទេសថៃ សិង្ហបុរី ម៉ាឡេស៊ី ជប៉ុន និងសាធារណរដ្ឋកូរ៉េ។ ទីចុងបញ្ចប់ ច្បាប់ស្តីពីទូរគមនាគមន៍ ត្រូវបានអនុម័ត និងចូលជាធរមានកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។

## ទី២-គោលបំណងនៃច្បាប់ស្តីពីទូរគមនាគមន៍៖

ច្បាប់ស្តីពីទូរគមនាគមន៍ មានគោលបំណងដើម្បី ធានាគុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍, ការពារ និងលើកទឹកចិត្តប្រតិបត្តិករក្នុងការវិនិយោគលើវិស័យទូរគមនាគមន៍, ការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកប្រើប្រាស់, និងកៀរគរចំណូលជាតិ។

## ទី៣-អត្ថន័យនៃមាត្រាមួយចំនួននៃច្បាប់ ដែលមានការបកស្រាយផ្ទុយពីការពិត៖

- **មាត្រា ៩៧៖**

  **កថាខណ្ឌទី១** "ការលបស្តាប់ឬការលបថតការសន្ទនា ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ដោយបុគ្គលដែលពុំភាគីនៃការសន្ទនាត្រូវផ្តន្ទាទោសពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងត្រូវទទួលពិន័យជាប្រាក់ពី ១០០,០០០ (១សែន)រៀល ទៅ ២,០០០,០០០ (ពីរលានរៀល)។

  *កថាខណ្ឌនេះ សំដៅការការពារឯកជនភាព សន្តិសុខ និងសុវត្ថិភាពនៃអ្នកប្រើប្រាស់សេវាទូរគមនាគមន៍ ដូចដែលមានចែងក្នុងមាត្រា ៦៥ (ស្តីពីសិទ្ធិមូលដ្ឋានរបស់អ្នកប្រើប្រាស់) ចំណុច ខ។*

**<u>កថាខណ្ឌទី២</u>** "បទប្បញ្ញត្តិកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តទេក្នុងករណីដែលការស្តាប់ឬការថតការសន្ទនានោះធ្វើឡើងដោយមានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធ ឬដោយមានការអនុញ្ញាតពីអាជ្ញាធរធម្មានុរូប។"

*កថាខណ្ឌទី២ ចំនុច <u>"ដោយមានការអនុញ្ញាតពីអាជ្ញាធរធម្មានុរូប"</u> សំដៅលើកលែងចំពោះប្រតិបត្តិការទូរគមនាគមន៍ដោយអាជ្ញាធរដែលពាក់ព័ន្ធនឹងការងារសន្តិសុខជាតិ និងការពារជាតិ ដោយយោងទៅលើវិសាលភាពនៃច្បាប់ដែលបានកំណត់ក្នុងមាត្រា៣ (**<u>មាត្រា៣ "វិសាលភាព"</u>៖** ច្បាប់ស្តីពីទូរគមនាគមន៍មានវិសាលភាពអនុវត្តគ្រប់ប្រតិបត្តិការទូរគមនាគមន៍ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាលើកលែងតែវិស័យសន្តិសុខ និងការពារជាតិ)។*

- **<u>មាត្រា ១១០</u>៖**

  ក្នុងរយៈពេល១(ឆ្នាំ)បន្ទាប់ពីច្បាប់នេះចូលជាធរមាន ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធវិស័យទូរគមនាគមន៍ត្រូវបំពេញទម្រង់បែបបទថ្មីនៅ **ន.ទ.ក** ដើម្បីសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត។

  លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលមានសពុលភាពក្រោយច្បាប់នេះចូលជាធរមាន ត្រូវអនុវត្តលក្ខខណ្ឌស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត។

  *មាត្រានេះ សំដៅកែសម្រួលទម្រង់ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់គ្រប់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធវិស័យទូរគមនាគមន៍ ដើម្បីធានាការប្រកួតប្រជែងដោយស្មើភាពក្នុងទីផ្សារទូរគមនាគមន៍ <u>និងមិនគ្រប់ដណ្តប់លើវិស័យសោតទស្សន៍នោះទេ</u>។*

ដូចនេះ ច្បាប់ស្តីពីទូរគមនាគមន៍ ត្រូវបានរៀបចំឡើងតាមនីតិវិធីយ៉ាងត្រឹមត្រូវ ស្របតាមស្តង់ដាអន្តរជាតិ ធានាការពារនូវផលប្រយោជន៍ស្របច្បាប់របស់តួអង្គពាក់ព័ន្ធក្នុងវិស័យទូរគមនាគមន៍ រួមមាន ប្រតិបត្តិករ អ្នកប្រើប្រាស់ និងរដ្ឋ ព្រមទាំងចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍន៍ប្រព័ន្ធទូរគមនាគមន៍ ឲ្យមានលក្ខណៈទំនើប គុណភាពខ្ពស់ ថ្លៃសមរម្យ និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នា ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិទី៥ នៃរដ្ឋសភា។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានការសោកស្តាយចំពោះការបកស្រាយផ្ទុយពីការពិតនូវអត្ថន័យនៃច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានធ្វើឡើងដោយអង្គការមួយនោះ គឺគ្មានតម្លាភាព ដោយគ្មានបានធ្វើការពិភាក្សាស្វែងយល់អំពីច្បាប់ជាមុនជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ក្រសួង សូមច្រានចោលទាំងស្រុងចំពោះការលើកឡើងថា ច្បាប់ស្តីពីទូរគមនាគមន៍បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងឯកជនភាពរបស់បុគ្គលគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សូមស្វាគមន៍ចំពោះការចង់សិក្សាស្វែងយល់ ក៏ដូចជាការចង់ទទួលបាននូវការផ្សព្វផ្សាយអំពីច្បាប់ស្តីពីទូរគមនាគមន៍សម្រាប់គ្រប់តួអង្គពាក់ព័ន្ធ។



រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦